# ការបោះឆ្នោតតាមសំបុត្របន្ទាន់

សន្លឹកឆ្នោតសម្រាប់បោះតាមសំបុត្រ ដែលបានចេញអោយប្រើនៅក្នុងរយៈពេលប្រាំមួយ (6) ថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅចំថ្ងៃបោះឆ្នោត ត្រូវបានគេហៅថា សន្លឹកឆ្នោតបោះតាមសំបុត្របន្ទាន់ (Emergency Vote By Mail Ballots) ។ សន្លឹកឆ្នោតទាំងនេះ***មិនអាច*** ផ្ញើចេញតាមសេវាប្រៃសណីយ៍ទាន់ពេលទេ។

ដើម្បីស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្របន្ទាន់, នោះអ្នកបោះឆ្នោត ឬតំណាងមានសិទ្ធិអនុញ្ញាតរបស់អ្នកបោះឆ្នោតត្រូវតែធ្វើលិខិតស្នើសុំជាលាយលក្ខណ៍អក្សរ ទៅមន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា ឬស្មៀនខោនធី ។

លិខិតស្នើសុំត្រូវតែមានផ្ទុកនូវព័ត៌មាន ដែលបានបង្ហាញជូនលើទម្រង់ខាងក្រោមនេះ ។

## ទម្រង់ដាក់ពាក្យសុំបោះឆ្នោតតាមសំបុត្របន្ទាន់

(ក្រមបោះឆ្នោត មាត្រាទី 3021 (Election Code Section 3021))

ជូនចំពោះ មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា ឬស្មៀនខោនធី LOS ANGELES

នៅថ្ងៃដែលការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅ ______________________________, ខ្ញុំមិនអាចធ្វើដំណើរទៅកាន់ការិយាល័យបោះឆ្នោតរបស់

ខ្ញុំបានទេ ហេតុដូច្នេះ ខ្ញុំសូមអនុញ្ញាតអោយ ____________________________________ យកសន្លឹកឆ្នោតរបស់ខ្ញុំ មកអោយខ្ញុំ ។
ខ្ញុំយល់ថា សន្លឹកឆ្នោតនេះមិនអាចផ្ញើទៅវិញតាមសេវាប្រៃសណីយ៍ទាន់ពេលទេ ដូច្នេះ ខ្ញុំឬតំណាងរបស់ខ្ញុំត្រូវតែយកវាទៅប្រគល់ជូនមន្ត្រីរៀបចំការបោះឆ្នោត ឬការិយាល័យបោះឆ្នោតណាមួយនៅក្នុងខោនធី Los Angeles ដោយផ្ទាល់ដៃ អោយទាន់មុនម៉ោង 8 យប់ នៅចំថ្ងៃបោះឆ្នោតជាកំហិត ។

ឈ្មោះរបស់អ្នកបោះឆ្នោតដោយសរសេរជាអក្សរផ្ចង់

______________________________________________

អាសយដ្ឋានរបស់អ្នកបោះឆ្នោតដោយសរសេរជាអក្សរផ្ចង់

______________________________________________

ក្រុង និងលេខសុិបកូដ

______________________________________________

ខ្ញុំសូមបញ្ជាក់ក្រោមទោសបញ្ញត្តិនៃការស្បថបំពានថា ព័ត៌មានដែលខ្ញុំបានផ្តល់ជូនពីខាងដើមទាំងប៉ុន្មានគឺសុទ្ធតែពិតប្រាកដ និងត្រឹមត្រូវ ។

អ្នកបោះឆ្នោតត្រូវតែចុះហត្ថលេខានៅត្រង់នេះ

______________________________________________

បានធ្វើឡើងដោយខ្ញុំបាទ / នាងខ្ញុំនៅ ____________________________________________, រដ្ឋ California នៅថ្ងៃទី
____________ ខែ _________________, ឆ្នាំ 20 ____________។

ហត្ថលេខារបស់ជនដែលបានត្រូវអនុញ្ញាត អោយទទួលសន្លឹកឆ្នោតនេះ

______________________________________________

សម្រាប់គោលបំណងនៃការផ្តល់សន្លឹកឆ្នោតបោះតាមសំបុត្របន្ទាន់ (សន្លឹកឆ្នោតដែលបានចេញអោយប្រើនៅក្នុងរយៈពេល 6 ថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅចំថ្ងៃបោះឆ្នោត), នោះអ្នកតំណាងដែលមានសិទ្ធិអនុញ្ញាតមិនចាំបាច់ត្រូវតែជាសាច់ញ្ញាតិរបស់អ្នកបោះឆ្នោតនោះទេ។